ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សារលិខិតរំលែកមរណទុក្ខ

ផ្ញើជូន

## ឯកឧត្តម នាយឧត្តមសេនីយ៍ មុឹង សំផន រដ្ឋលេខាធិការ ក្រសួងការពារជាតិ

ឯកឧត្តម នាយឧត្តមសេនីយ៍ ជាទីស្រលាញ់រាប់អានដ៏ជ្រាលជ្រៅ !

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកជំទាវធម្មសទ្ធាភិរក្ខសិរីវិសុទ្ធិរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **យស់ ស៊ីមន** បានទទួលមរណភាពនាថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ វេលាម៉ោង១៨:៥២នាទី ក្នុងជន្មាយុ៧៨ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់លោកជំទាវធម្មសទ្ធាភិរក្ខសិរីវិសុទ្ធិរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **យស់ ស៊ីមន** មិនត្រឹមតែជាការបាត់បង់នូវភរិយា ម្តាយ និងជីដូនជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅ ប្រកបដោយព្រហ្មវិហារធម៌ និងសង្គហធម៌គម្រូមួយរូបដែលតែងតែខិតខំចិញ្ចឹម បីបាច់ថែរក្សា អប់រំ ទូន្មាន បុត្រធីតា និងចៅៗ រហូតក្លាយជាកុលបុត្រកុលធីតាដ៏ឆ្នើមរបស់សង្គមជាតិប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់នូវធនធានមនុស្សមួយរូប ដែលបានធ្វើពលិកម្មសព្វបែបយ៉ាង ដើម្បីរួមចំណែកគាំពារ និងជ្រោមជ្រែងឯកឧត្តម នាយឧត្តមសេនីយ៍ ក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តម ប្រកបដោយឆន្ទៈមនសិការដ៏មោះមុតក្នុងបុព្វហេតុជាតិ មាតុភូមិ។ លើសពីនេះទៅទៀត មរណភាពរបស់លោកជំទាវ គឺជាការបាត់បង់នូវពុទ្ធសាសនិកមួយរូប ដែលមានសទ្ធាជ្រះថ្លាយ៉ាងក្រៃលែង បានបូជាកម្លាំងកាយចិត្ត ធនធាន និងពេលវេលា ដើម្បីរួមចំណែកក្នុងការងារមនុស្សធម៌ និងទ្រទ្រង់លើកស្ទួយវិស័យព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់លោកជំទាវធម្មសទ្ធាភិរក្ខសិរីវិសុទ្ធិរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **យស់ ស៊ីមន** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម នាយឧត្តមសេនីយ៍ មុឹង សំផន រដ្ឋលេខាធិការ ក្រសួងការពារជាតិ ទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**